ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់ការកែប្រែមហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ ទៅជាសាកលវិទ្យាល័យមៀលធ្លាយ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦,០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការបង្កើត មហាវិទ្យាល័យគ្រប់គ្រង និង នីតិសាស្ត្រ
- បានឃើញលិខិតលេខ ០០៦/០២ស្ទន ម.គ.ន ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២ របស់ មហាវិទ្យាល័យ គ្រប់គ្រង និង នីតិសាស្ត្រ
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា ១ : ទទួលស្គាល់អោយ មហាវិទ្យាល័យ គ្រប់គ្រង និង នីតិសាស្ត្រ កែប្រែទៅជា " សាកលវិទ្យាល័យ

www.pheakdeylaw.com

បៀលប្រាយ "BUILD BRIGHT UNIVERSITY" ហៅកាត់ជាភាសាខ្មែរ "ស.ប.ប" និង ហៅកាត់ជាភាសាអង់គ្លេស "B.B.U" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងស្ថិតនៅ :

- ទីតាំងទី១ : អាគារប្រផេះ ផ្លូវលេខ ២៧៤ សង្កាត់ទន្លេ បាសាក់ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ។
- ទីតាំងទី២ : អាគារលេខ ៤៥ស ផ្លូវលេខ ២០៥ និង ៣៥៦ សង្កាត់ទួលស្វាយព្រៃទី ២ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ។
- ទីតាំងទី៣ : អាគារលេខ ២៨ ផ្លូវលេខ ២០០ សង្កាត់ផ្សារថ្មីទី៣ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។
- ទីតាំងទី៤ : ស្ថិតនៅភូមិវិហាចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្ត សៀមរាប ។

មាត្រា ២ : សាកលវិទ្យាល័យបៀលប្រាយ ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៧០ក្រេឌីត ។
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ។
- ថ្នាក់ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីត ។
- ថ្នាក់បណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ ត្រូវនឹង ៥៤ ក្រេឌីត ។

មាត្រា ៣ : សាកលវិទ្យាល័យបៀលប្រាយមាន :

១. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
២. មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
៣. មហាវិទ្យាល័យ នីតិសាស្ត្រ និង វិទ្យាសាស្ត្រសង្គម
៤. មហាវិទ្យាល័យ សិល្បៈ និង មនុស្សសាស្ត្រ
៥. មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ និង ភាសា

នៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យបៀលប្រាយ មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និងសំរេចលើគោលនយោបាយ និងផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ សំរាប់ពិនិត្យ និង ផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៥ : លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជន ត្រូវមានចំណេះដឹងទាបបំផុត បានសិក្សាបញ្ចប់ ថ្នាក់ទី ១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ: បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រ ដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជនទាំងពីរភេទ មានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

www.pheakdeylaw.com

សាកលវិទ្យាល័យត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើស សិស្ស និស្សិត អោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៦ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យបៀលប្រាយមានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើស សិស្ស-និស្សិត អោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៧ : និស្សិត ដែលរៀនចប់ កម្មវិធីសិក្សា របស់សាកលវិទ្យាល័យនេះ និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ទទួលសញ្ញាប័ត្រតាមកំរិតនិងតាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះត្រូវបានផ្តល់អោយដោយសាកលវិទ្យាល័យបៀលប្រាយ ហើយត្រូវបានទទួលស្គាល់ ពីក្រសួង អប់រំ យុវជន និង កីឡា ក្នុងករណីសាកលវិទ្យាល័យនេះបំពេញនិងអនុវត្តបានតាមគោលការណ៍របស់ក្រសួងអប់រំ យុវជននិងកីឡា ។

មាត្រា ៨ : រដ្ឋមន្ត្រី ទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យបៀលប្រាយ មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

មាត្រា ៩ : រាល់បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពី អនុក្រឹត្យនេះ ត្រូវចាត់ទុក ជានិរាករណ៍ ។

ភ្នំពេញ ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
- សាលាក្រុងសៀមរាប

"ដើម្បីមុខការ"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com